ក្រសួងធម្មការ និង សាសនា

# សាមណេរ
# សុខា



អត្ថបទ© ក្រសួងធម្មការ និងសាសនា និង UNICEF
រចនាទំព័រ© SIPAR ២០១៦
គំនូរ© សេង វិសុទ្ធ ២០១៦

**ក្រសួងធម្មការ និងសាសនា**
អាសយដ្ឋាន ៖
លេខ៣៩៣ តិរវិថីស៊ីសុវត្ថិ សង្កាត់ជ័យជំនះ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: +៨៥៥ ២៣ ៧២២ ៦៩៩
អ៊ីម៉ែល: mocar@cambodia.gov.kh
គេហទំព័រ: http://ww.mocar.gov.kh
រាជធានីភ្នំពេញ ខែមករា ឆ្នាំ២០១៦

# សាមណេរសុខា



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធម្មការ និង សាសនា**
**លេខ ២៦៩/១៦ ក.ធ.ស**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវក្នុងឆ្នាំ ២០១៣ ស្តីពីអំពើហិង្សាលើកុមារបានផ្តល់នូវទិន្នន័យ និងការប៉ាន់ស្មានកម្រិតថ្នាក់ជាតិលើកដំបូង ស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជាបានបង្ហាញថា អំពើហិង្សាជាបញ្ហាចំបងមួយសម្រាប់កុមារកម្ពុជា ដែលមានកុមារានិងកុមារីជាច្រើនបានទទួលរងនូវអំពើហិង្សាគ្រប់ភេទ។ កុមារត្រូវបានគេរំលោភបំពាន ដោយអ្នកដែលកុមារស្គាល់ និងទុកចិត្ត រួមទាំងឪពុកម្តាយកុមារ និងគ្រូបង្រៀនរបស់ពួកគេ នៅទីកន្លែងដែលគួតែជាកន្លែងមានសុវត្ថិភាពសម្រាប់ពួកគេ រួមទាំងនៅផ្ទះ និងសាលារៀន។ ក្នុងនោះកុមារភាគច្រើន មិនដែលបាននិយាយប្រាប់នរណាម្នាក់អំពីការទទួលរងគ្រោះទាំងនេះទេ ហើយបានរកជំនួយដោយខ្លួនឯង។ អំពើហិង្សាលើកុមារ មានផលប៉ះពាល់ដល់ការអភិវឌ្ឍន៍ផ្លូវចិត្ត កាយ និងមិនឱយកុមារទទួលបាននូវការរីកលូតលាស់ប្រកបដោយសក្តានុពល។ អំពើហិង្សាបង្រៀនឱយមានអំពើហិង្សា-បញ្ឈប់វដ្តនៃអំពើហិង្សាដោយការទប់ស្កាត់។

ព្រះពុទ្ធសាសនានៅកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់តម្លៃសីលធម៌ និងធម៌អហិង្សា ក៏ដូចជាទ្រទ្រង់នូវអរិយធម៌ វប្បធម៌ជាតិទាំងមូល។ ព្រះសង្ឃ ជាឧត្តមភេទដែលប្រជាជនខ្មែរស្តាប់តាម និង គោរពប្រណិប័តន៍ ដែលជាការគោរពមានប្រភពពី វប្បធម៌ ប្រពៃណី បទដ្ឋានសង្គមដោយពុទ្ធសាសនិកកម្ពុជា។ ហេតុដូចនេះ ព្រះសង្ឃអាចមានសង្ឃដីកាជាមួយពុទ្ធបរិស័ទនូវបញ្ហារសើប និងជួយដោះស្រាយនូវបទដ្ឋានសង្គម នឹងការអនុវត្តមួយចំនួនដែលបង្កហានិភ័យ។ វត្ត និងព្រះសង្ឃផ្សារភ្ជាប់ជាមួយជីវភាពប្រចាំថ្ងៃរបស់ពុទ្ធបរិស័ទតាមរយៈ ការផ្តល់ឱវាទ ទេសនា សូត្រមន្ត និមន្តបិណ្ឌបាតចង្ហាន់តាមភូមិចំណុះជើងវត្ត ជាទីកន្លែងដែលកើតមាននូវអំពើហិង្សា និងបញ្ហាគ្រប់យ៉ាងកើតមានឡើង និងក៏ជាទីកន្លែងរស់នៅរបស់កុមារជនប្រព្រឹត្តហិង្សាផងដែរ។ ការចូលរួមរបស់ព្រះសង្ឃក្នុងការទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើកុមារគឺជាសកម្មភាពរួមចំណែកដោយមានប្រសិទ្ធភាព និងសុក្រិតភាពបំផុតទាំងរូបភាពនិងទ្រឹស្តីរបស់ព្រះពុទ្ធសាសនា។

ក្រសួងធម្មការនិងសាសនា ដែលជាស្ថាប័នរដ្ឋទទួលខុសត្រូវលើជំនឿសាសនារបស់ប្រជាពលរដ្ឋ ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខរាជរដ្ឋាភិបាល មានទស្សនៈទូលំទូលាយប្រកប ដោយគតិបណ្ឌិតក្នុងការដឹកនាំជាតិ បាននឹងកំពុងធ្វើការអភិវឌ្ឍជាតិយ៉ាងយកចិត្តទុកដាក់ខ្ពស់ ដើម្បីលើកកម្ពស់សីលធម៌ ប្រជាពលរដ្ឋកម្ពុជាសំដៅ កាត់បន្ថយ និងឈានទៅរកការលប់បំបាត់អំពើហឹង្សា តាមរយៈសាសនា។

សៀវភៅ "សាមណេរ សុខា" នេះ ជាសមិទ្ធផលថ្មីមួយ របស់ក្រសួងធម្មការ និងសាសនា សហការជាមួយ គណៈសង្ឃនៃព្រះរាជាណាចក្រកម្ពុជា ផលិតឡើងក្នុងគោលបំណងលើកកម្ពស់សមត្ថភាពរបស់ព្រះសង្ឃក្នុងការចូលរួមទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ។

សូមថ្លែងអំណរគុណ ចំពោះអង្គការ UNICEF ប្រចាំកម្ពុជាដែលបានផ្តល់ការគាំទ្រទាំងបច្ចេកទេស និងថវិការ ក្នុងការផលិតសៀវភៅរឿងនេះឡើង។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រី**

**មិន.ឃិន**

# 393, តិវិថី ព្រះស៊ីសុវត្ថិ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh


នេះជារឿងរបស់សុខា ក្មេងប្រុស
អាយុ១២ឆ្នាំម្នាក់ ដែលរស់នៅជាមួយគ្រួសារ
ក្នុងភូមិតូចមួយ នៅខេត្តកណ្តាល។


គ្រួសារសុខាមានតែអំពើហិង្សា។ គ្រួសារនេះ
រកសេចក្តីសុខមិនឃើញសោះ។ សុខាមិនអាចប្រមូល
អារម្មណ៍រៀនបានទេ ហើយទីបំផុតគេក៏ឈប់រៀន។


ឪពុកសុខាមិនមែនជា
មនុស្សអាក្រក់ទេ
តែពេលគាត់ស្រវឹងម្តងៗ
គាត់តែងវាយ
និងជេរម្តាយសុខា។


ពីមួយថ្ងៃទៅមួយថ្ងៃ ឪពុកសុខាផឹកស្រាច្រើនទៅៗ
ហើយអំពើហិង្សាក្នុងគ្រួសារក៏មានស្ទើរតែរាល់ថ្ងៃដែរ។


ពេលឪពុកម្ដាយសុខាមួរម៉ៅ ឬឈ្លោះគ្នា ពួកគាត់តែងជះកំហឹងលើកូនៗ។
ឱ្យខ្ញុំគេងលក់យ៉ាងម៉េច បើក្នុងផ្ទះនេះស្គាល់តែទុក្ខ ? ពិបាកចិត្តណាស់ !
ថ្ងៃមួយ...
ចេញឱ្យឆ្ងាយអាឆ្កែឆ្កួត !
សុភី ! ឯងចេះធ្វើអីចឹងមកពីណា ?
ពុកម៉ែតែងវាយ ហើយស្រែកដាក់ខ្ញុំ និងសុភី។ យើងមិនសប្បាយចិត្តទេ មិនតែប៉ុណ្ណោះយើងខ្លាចពួកគាត់ទៀត។ ប្រហែលគ្មានអ្នកណាស្រលាញ់ពួកយើងទេ។
ចំណែកខ្ញុំ ពេលខឹងសុភីម្ដងៗ ខ្ញុំក៏តែងជេរ ហើយវាយវាដែរ។ តែរួចហើយខ្ញុំតែងស្ដាយក្រោយ ហើយខ្ញុំមិនដឹងថា ហេតុអីខ្ញុំធ្វើបែបនេះទេ។ ខ្ញុំធុញនឹងជីវិតបែបនេះណាស់។ គួរតែធ្វើអ្វីម្យ៉ាង !


រាល់ពេលដែលឪពុកម្ដាយសុខា វាយតប់គ្នា សុខាតែងសុំឱ្យ អ្នកជិតខាងជួយ។ តែពួកគេ មិនខ្វល់ ព្រោះវាជារឿងធម្មតា សម្រាប់ពួកគេ។
ប្រាប់មក៏ ស្រីចង្រៃ! ឯងលាក់លុយ កន្លែងណា? យើងចង់ទៅផឹក!
មានលុយមកពីណា! ឯងយកវាទៅផឹក អស់ហើយ។ ផឹកៗ គ្មានបានការអីសោះ!
យើងស្អប់គ្រួសារហ្នឹងណាស់។ វ៉ៃគ្នា មិនថាយប់ មិនថាថ្ងៃទេ។ គួរតែ ដោះស្រាយហើយ។
វាមិនមែនជារឿងយើងទេ! ម្យ៉ាងទៀត វាធម្មតាទៅហើយ!
អេហ៍! ខំប្រឹង និយាយទៅ យើងជិត ឈ្នះហើយ! ហាសហា!
យើងគិតថា វាជាកំហុស ប្រពន្ធ។ នាងហ្នឹងមិនដែល មើលផ្ទះសំបែងអីទេ។ គិតតែពីឈឺទៀត!
មែនហ្នឹង... តែកុំទៅខ្វល់ អីរឿងគេ!
ពូ មីង ជួយម៉ែខ្ញុំ ផង!

# សំណួរត្រិះរិះ ១

១- តើសុខាបានជួបអំពើហិង្សាប្រភេទណាខ្លះ ? តើមានអំពើហិង្សាក្នុងរូបភាពផ្សេងទៀតដែរឬទេ ? អ្វីខ្លះ ?

២- តើអំពើហិង្សាប៉ះពាល់អារម្មណ៍សុខាយ៉ាងដូចម្ដេចខ្លះ ?

៣- តើសុខាគួរតែទទួលបានអ្វីពីគ្រួសារវិញ ?

៤- តើប្ដីវាយធ្វើបាបប្រពន្ធ អាចទទួលយកបាន ឬទេ ?

១- សុខាទទួលរងហិង្សាលើរាងកាយ រួមមានការវាយដំ ទះតប់ ឬវាយនឹងវត្ថុផ្សេងៗ។ ឪពុកម្ដាយតែងវាយសុខាក្នុងគោលបំណងអប់រំ។ យើងហៅអំពើបែបនេះថា ហិង្សាលើរាងកាយ។ សុខាក៏ធ្លាប់ទទួលរងអំពើហិង្សាផ្នែកសតិអារម្មណ៍ដែរ ដូចជាស្ដីបន្ទោស ជេរប្រទេចផ្ដាសា រួមទាំងការមិនយកចិត្តទុកដាក់។ តាមរយៈបទពិសោធន៍ផ្ទាល់របស់សុខា គេទទួលរងអំពើហិង្សានេះនៅក្នុងផ្ទះ ដែលយើងហៅថា អំពើហិង្សាក្នុងគ្រួសារ។ ហិង្សាមានក្នុងរូបភាពផ្សេងៗទៀត រាប់បញ្ចូលទាំងហិង្សាផ្នែកសេដ្ឋកិច្ច ហិង្សាលើផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្ម។

២- សុខាកើតទុក្ខ អស់សង្ឃឹម ខ្មាសគេ មួម៉ៅ និងមានអារម្មណ៍បរាជ័យ ហាក់ដូចជាធ្វើខុសអ្វីមួយ។ គេគេងមិនលក់ ហើយតែងតែសុបិនអាក្រក់នៅពេលយប់។ សុខាមិនអាចប្រមូលអារម្មណ៍ក្នុងការសិក្សា ហើយចុងក្រោយ គេក៏សម្រេចចិត្តឈប់រៀន។

៣- អំពើហិង្សាមិនមែនជាដំណោះស្រាយល្អទេ។ សុខាគួរតែទទួលបានក្ដីស្រលាញ់ ការគាំទ្រ និងការការពារពីគ្រួសារគ្រប់វិនាទី។

៤- មិនអាចទទួលបានទេ។ ច្បាប់ហាមឃាត់នូវរាល់អំពើហិង្សានានាក្នុងគ្រួសារ។ ឪពុកសុខាត្រូវបញ្ឈប់ការវាយធ្វើបានម្ដាយសុខា។


ថ្ងៃមួយ...
ទាន់ចង្ហាន់លោកទេ ?
ទាន់ចង្ហាន់លោកទេ ?
ផាន់នី! អាត្មាឃើញថា ញោម មានរបួស។ តើញោមអាចប្រាប់អាត្មាបានទេថាមានរឿងអ្វីកើតឡើង ?
...
ម៉េចក៏ម៉ែនៅស្ងៀមអីចឹង ?
ថ្ងៃបន្ទាប់ សុខាក៏សម្រេចចិត្តទៅវត្ត ដើម្បីជួបព្រះចៅអធិការ។
លោកគ្រូព្រះចៅអធិការ ខ្ញុំករុណាមានរឿងចង់ប្រាប់...


សុខារៀបរាប់ប្រាប់ចៅអធិការអំពី
ស្ថានភាពក្នុងគ្រួសារគេ។


លោកគ្រូ
ព្រះចៅអធិការ
សូមជួយទៅនិយាយ
ជាមួយពុកម៉ែខ្ញុំករុណា
ហើយជួយនាំ
សេចក្តីសុខមក
គ្រួសារខ្ញុំផង។


ព្រះចៅអធិការ មកផ្ទះសុខានៅថ្ងៃបន្ទាប់ហើយ មានសង្ឃដីកាជាមួយឪពុកម្ដាយសុខា។
មើលប្រពន្ធញោមចុះ! ឈប់វាយ ធ្វើបាបនាងទៅ។ អ្វីដែលញោមធ្វើ គឺកំពុង បំផ្លាញគ្រួសារ ប្រពន្ធ និងកូនៗ។ ត្រូវបញ្ឈប់វាយ ប្រពន្ធ និងកូនៗញោមទៀតទៅ។
អំពើហិង្សាលើកុមារ គឺមិនត្រឹមត្រូវ ឡើយ។ ឪពុកម្ដាយមិនត្រូវវាយកូនឡើយ។ សុរានាំមកនូវភាពអន្តរាយ។ មិនត្រឹមតែ ប៉ះពាល់សុខភាពទេ តែវាជាប្រេង សម្រាប់បញ្ឆេះអំពើហិង្សាផងដែរ។
១
នេះគឺអ្វី ដែលហៅថា គ្រួសារ រីករាយ។
តែបើមានការ វាយដំ ឬជេរ ប្រទេចផ្ដាសាកើត ឡើង ពេលនោះ គ្រួសាររីករាយ នឹងត្រូវបំផ្លាញ។
២
៣
ញោមគិតថាការវាយកូន គឺជាការអប់រំដែលចាំបាច់ មែនទេ? ហើយបើមិនវាយ ពួកគេនឹងខូចឬ?
៤
ខុសហើយ! ការវាយកូន ទោះបីជា ស្រាលដៃក៏ដោយ ក៏វាប៉ះពាល់ដល់ ការលូតលាស់របស់គេដែរ។ កូននឹង ធំឡើងក្នុងភាពភ័យខ្លាចនិងមិនជឿ ជាក់លើអ្នកទាំងពីរ។ ពេលនោះ ទំនាក់ ទំនងគ្រួសារ នឹងត្រូវរលាយអស់។


កូនរៀនពីឪពុកម្តាយ។ គេធ្វើអ្វីដែលគេបានឃើញ។
បើរាល់ថ្ងៃ ឪពុកម្តាយប្រើអំពើហិង្សាទៅលើពួកគេ
គេនឹងធ្វើអំពើដូចគ្នាទៅលើអ្នកផ្សេង...
... ព្រោះពួកគេគិតថា អំពើហិង្សាជារឿងធម្មតា។
គេនឹងប្រើវាទៅលើអ្នកដទៃ ដោយមិនដឹងខ្លួន ដូចសុខា
បានប្រាប់អាត្មាថា គេធ្លាប់វាយប្អូនស្រីគេអីចឹង។
ចំណែកសុភីវិញ នាងចេះទាត់ឆ្កែ នៅពេលនាង
ខឹង។ បើញោមចង់ឱ្យកូនក្លាយជាមនុស្សល្អ
អ្នកទាំងពីរគួរតែធ្វើឱ្យពួកគេឃើញសិន។




ព្រះចៅអធិការរំលឹក ឪពុកម្ដាយសុខាម្ដង ហើយម្ដងទៀតឱ្យគោរព តាមគោលការណ៍ទាំង៥។

ត្រូវដឹងថា ខ្លួនជាឪពុកម្ដាយគេ។ កូនៗនឹងធ្វើតាមអ្នក។ ធ្វើជាមនុស្សល្អប្រសិនបើ ចង់ឱ្យកូនអ្នកក្លាយជា មនុស្សល្អ។

វាយតប់មិន បានជួយកូនៗទេ តែ ធ្វើឱ្យពួកគេខ្លាច ហើយ ប៉ះពាល់ដល់អារម្មណ៍។ ពួកគេនឹងខ្លាចឪពុក ម្ដាយគេ។

វាយតប់ មិនបានបង្រៀនកូនៗ ឱ្យស្គាល់ អ្វីហៅថាខុស អ្វីហៅថាត្រូវនោះទេ។

វាយតប់ និងបន្ទោស គឺធ្វើឱ្យ ខូចទំនាក់ទំនងជាមួយ កូនៗ។ ពួកគេនឹងមិន ជឿជាក់លើអ្នក ទាំងពីរ។

វាយតប់ អាចឱ្យកូនស្ដាប់បង្គាប់ តែមិនធ្វើឱ្យគេគោរពទេ។ គេនឹងមិនដឹងថា គេបាន ធ្វើអ្វីខុសទេ។

# សំណួរត្រិះរិះ ២

១- តើយើងអាចប្រើអំពើហិង្សា ដើម្បីអប់រំកូនបានដែរឬទេ? បើមិនបាន ហេតុអ្វី?

២- តើអំពើហិង្សាបង្រៀនអ្វីខ្លះដល់កុមារ?

៣- តើពាក្យថា *ស្រាឬសុរាជាប្រេងសម្រាប់បញ្ឆេះអំពើហិង្សា* មានន័យយ៉ាងដូចម្តេច?

១- ការធ្វើទណ្ឌកម្មជាអំពើមិនត្រឹមត្រូវព្រោះ ៖

- វាធ្វើឱ្យកុមារមានអារម្មណ៍ត្រូវគេបោះបង់ ឯកា និងសោកសៅ។ វាបង្រៀនកុមារឱ្យខ្លាចញញើត។
- អំពើហិង្សាប៉ះពាល់ដល់ការលូតលាស់របស់កុមារ ហើយធ្វើឱ្យខួរក្បាលពួកគេលូតលាស់យឺត។
- ការវាយតប់ធ្វើឱ្យប៉ះពាល់ខ្លាំងដល់ទំនាក់ទំនងរវាងឪពុកម្តាយនិងកូន។
- វាធ្វើឱ្យឈឺចាប់ និងខាតប្រយោជន៍កាន់តែខ្លាំង។

២- កុមារចម្លងតាមការប្រព្រឹត្តរបស់ឪពុកម្តាយគេ គឺគេធ្វើតាមអ្វីដែលគេបានឃើញ! កុមារដែលឃើញឪពុកម្តាយរបស់គេប្រើអំពើហិង្សាគេនឹងគិតថា ហិង្សាជារឿងធម្មតា និងអាចធ្វើបាន។ គេនឹងគិតទៀតថា វាជាវិធីមួយសម្រាប់បង្ហាញពីអារម្មណ៍របស់យើង។ នៅពេលដែលពួកគេធំឡើង គេនឹងចូលចិត្តប្រើអំពើហិង្សា ឬព្រមទទួលយកហិង្សាដែលមានលើគេ។ វាថែមទាំងបង្រៀនឱ្យកុមារយល់ថាមនុស្សដែលគេតែងរំពឹងថានឹងការពារគេ( ឪពុកម្តាយបែរជាធ្វើបាបគេ )។ វាធ្វើឱ្យកុមារគិតថាឪពុកម្តាយ និងផ្ទះរបស់គេជាកន្លែងគ្មានសុវត្ថិភាពឡើយ។ វាធ្វើឱ្យគេជឿជាក់ថាក្តីស្រលាញ់ និងហិង្សាមានទំនាក់ទំនងគ្នា។

៣- សុរាធ្វើឱ្យយើងបាត់បង់ការគ្រប់គ្រងខ្លួនឯង ហើយអាចឱ្យយើងធ្វើអ្វីដែលយើងមិនដែលធ្វើពីមុនមក។ សុរាអាចបង្កើន កម្លាំងបាយឈ្លានពានទៅលើអ្នកដទៃ។ ការប្រកែកតិចតួចអាចក្លាយជាទំនាស់ធំ។ នៅពេលមនុស្សម្នាក់ស្រវឹងគេនឹងបាត់បង់ការគិត ហើយគេនឹងលែងឃើញពីផលអាក្រក់នៃទង្វើរបស់គេ។ សុរាគឺបំផ្លាញគ្រួសារទាំងមូលឱ្យបែកខ្ញែក។


បន្តិចម្តងៗ...
គ្រួសារសុខាបានយល់ពីបញ្ហាអំពើហិង្សា ហើយពួកគេរស់នៅដោយសុភមង្គល។
ពុក ខ្ញុំទៅបួស បានអត់?
បានសុខា! វាក៏ល្អដែរ ឯងនឹងបាន រៀនសូត្រ។ ពុកនឹងទៅសុំព្រះចៅ អធិការឱ្យជួយ។
បើសុខាចង់ក្លាយជាព្រះសង្ឃ អាត្មារីករាយនឹងទទួលគេ។
ឪពុកម្តាយសុខាក៏អនុញ្ញាតឱ្យគេ បួសជាសាមណេរដែរ។


ក្រោយពីបានគ្រងជីពរ
ក្លាយជាសាមណេរហើយ
សុខាចាប់ផ្តើមរៀន
ជាមួយព្រះចៅអធិការ។
សាមណេរសុខា
ស្វាធ្យាយទន្ទេញធម៌តែអង្គឯង។


ព្រះពុទ្ធសាសនាជាសាសនា ដែលបង្រៀន និងណែនាំមនុស្សឱ្យ គ្មានអំពើហិង្សាក្នុងគ្រួសារ និងសង្គម។
ពេលបួសជាព្រះសង្ឃ សុខាចាប់ផ្តើមរៀននៅក្នុងវត្ត។ ក្នុងថ្នាក់ ព្រះចៅអធិការបង្រៀនសិស្សឱ្យដឹងថា ព្រះសង្ឃអាចជួយបញ្ឈប់អំពើហិង្សាក្នុងគ្រួសារបាន។


យើងអាចយកពុទ្ធសាសនា ដើម្បីបង្រៀនឪពុកម្តាយ កុំឱ្យប្រើអំពើហិង្សា កុំជេរ និងកុំបន្ទោសកូនៗ។
ព្រះសង្ឃ គឺជាតួអង្គគំរូក្នុងសង្គម ដើម្បីអប់រំសតិអារម្មណ៍របស់មនុស្ស។
អ្នកភូមិគោរព និងជឿជាក់លើព្រះសង្ឃ។ពួកគេតែងគោរពនូវដំបូន្មានរបស់យើង។ យើងក៏អាចនិយាយពន្យល់ប្រជាជនអំពីបញ្ហាដែលធ្ងន់ធ្ងរ ដូចជាអំពើហិង្សា ដែលគ្មានអ្នកណាចង់និយាយបានដែរ។


ថ្ងៃមួយ ព្រះចៅអធិការ
នាំសាមណេរសុខាទៅភូមិ។
ថ្ងៃនេះ ខ្ញុំព្រះករុណានឹងបង្ហាញ
សាមណេរឯងអំពីអ្វីដែលយើងបានរៀន
ក្នុងវត្តមកអនុវត្ត។
សាមណេរសុខា! ក្នុងនាមជាព្រះសង្ឃ
វាជាការងាររបស់យើងក្នុងការគាំទ្រសិទ្ធិកុមារ។ យើងត្រូវ
ប្រាប់គ្រួសារឱ្យដឹងអំពីផលវិបាកនៃអំពើហិង្សា។ យើងអាចបង្រៀន
អំពីសីលប្រាំ។ យើងអាចឱ្យដំបូន្មានដល់ឪពុកម្តាយ
ឱ្យមានគុណធម៌ ចំពោះកូនៗ។ ដូចអ្វីដែលខ្ញុំព្រះករុណា
ធ្លាប់ប្រាប់ទៅគ្រួសាររបស់ សាមណេរដែរ។ ទាំងនេះ
ជាអ្វីដែលព្រះសង្ឃអាចបង្កើតសន្តិភាពក្នុងសង្គមបាន។
មើលពួកគេចុះ!
គេមិនអាចទប់កំហឹងគេបានទេ។
យើងត្រូវជួយឃាត់ពួកគេ។
ភ្លាមនោះ...


ព្រះចៅអធិការចូលទៅឃាត់ ហើយមានសង្ឃដីកាជាមួយពួកគេ។ ពួកគេគោរព ហើយឈប់ឈ្លោះគ្នា។


សាមណេរសុខា នៅពេលដែលយើងខឹង វាជាពេលដែលយើងត្រូវប្រយ័ត្ន។ បើមិនអើពើទេ កំហឹងនឹងក្លាយទៅជាអំពើហិង្សា។
តើយើងអាចរំងាប់កំហឹងបានយ៉ាងម៉េចទៅ ព្រះចៅអធិការ ?


ចាំខ្ញុំព្រះករុណា
ប្រគេនឧទាហរណ៍ខ្លះ។
1
យើងអាចដកដង្ហើមចូល
ហើយរាប់ពី១ដល់១០...
2
យើងអាចដើរចេញពី
បញ្ហា ហើយរង់ចាំរហូត
ដល់យើងស្ងប់អារម្មណ៍
ឡើងវិញ...
3
ហាត់ប្រាណ ឬ
លេងកីឡា ដើម្បី
រំងាប់អារម្មណ៍...
4
... ឬយើងអាចប្រាប់
គេឱ្យធ្វើសមាធិ។ វាអាច
ជួយឱ្យអារម្មណ៍យើង
ស្ងប់បាន។


តែសាមណេរដឹងទេថា ករណីខ្លះ
អាចបញ្ចប់បានយ៉ាងស្រួល ដូចជាគ្រួសាររបស់
សាមណេរអីចឹង។ តែខ្លះទៀតមិនងាយបញ្ចប់ទេ។ ដូច្នេះ
បើមានករណីធ្ងន់ធ្ងរដូចជា ការរំលោភ ឬគ្រួសារមិនព្រម
បញ្ចប់ យើងអាចប្ដឹងប៉ូលិស ឬប្រាប់ប្រធានភូមិ។


ត្រលប់មកក្នុងថ្នាក់វិញ...
នៅថ្ងៃណាមួយ នឹងមានអ្នកខ្លះចាកចេញ ពីសាមណេរ ហើយអ្នកខ្លះនឹងបន្តនៅជាព្រះសង្ឃ។ បើអ្នកទាំងអស់គ្នាសម្រេចចិត្តហើយ ចូរកុំភ្លេចដំបូន្មាន របស់ខ្ញុំព្រះករុណាឱ្យសោះ។
ដើរឱ្យរំពៃ អង្គុយឱ្យសញ្ជឹង ខឹងឱ្យពិចារណា ប្រើហិង្សាឱ្យគិតដល់ក្មេង។ ត្រូវដឹងថា រស់នៅមានក្ដីសុខ គឺមិនបៀតបៀន អ្នកដទៃ។


ពេលលាចាកសិក្ខាបទ ហើយ ចូរកុំផឹកស្រា កុំប្រើ អំពើហិង្សា! វានឹងធ្វើឱ្យ ប៉ះពាល់ដល់តម្លៃមនុស្សធម៌ ហើយថែមទាំងនាំឱ្យ អាប់ឱនព្រះពុទ្ធសាសនា។
ធ្វើជាគំរូល្អដល់អ្នកដទៃ។ ជួយ អប់រំអ្នកដទៃផ្នែកសតិអារម្មណ៍។ ធ្វើជាគំរូល្អ មានន័យថា គោរពអ្នកដទៃ។ វាក៏មានន័យថា គាំទ្រភាពគ្មានអំពើហិង្សា។

# សំណួរត្រិះរិះ ៣

១-តើព្រះពុទ្ធសាសនាអាចបញ្ចៀស ឬបញ្ឈប់អំពើហិង្សាបានដោយរបៀបណា ?

២-តើអ្វីទៅដែលធ្វើឲ្យព្រះសង្ឃជាមនុស្សម្នាក់គត់ដែលអាចបញ្ឈប់អំពើហិង្សាទៅលើកុមារ ?

១-

- ព្រះពុទ្ធសាសនាជាសាសនាសន្តិភាពមួយដែលបានលើកកម្ពស់អហិង្សាក្នុងសង្គម និងយកចិត្តទុកដាក់លើសុខមាលភាពរបស់សត្វលោក។
- ធម៌ព្រះពុទ្ធបង្រៀនមនុស្សឱ្យក្លាយជាមនុស្សថ្លៃថ្នូ មានករុណាធម៌ ចេះទទួលខុសត្រូវនិងបង្រៀនពួកគេឱ្យចេះរស់នៅជាមួយគ្នាប្រកបដោយសុភមង្គល។

២-

- ព្រះសង្ឃដឹកនាំផ្លូវចិត្តប្រជាជនខ្មែរ ហើយទ្រង់ក៏ជាតំណាងសីលធម៌សង្គម។
- សហគមន៍ និងគ្រួសារទៅជួបព្រះសង្ឃដើម្បីទទួលយកដំបូន្មាន និងការតម្រង់ផ្លូវ។
- ព្រះសង្ឃត្រូវបានមនុស្សទូទៅគោរព និងស្តាប់បង្គាប់ ៖ មនុស្សទាំងអស់នឹងស្តាប់តាមព្រះសង្ឃ ក្នុងផ្លូវមួយដែលគេមិនធ្វើទៅលើអ្នកដទៃ។ ទាំងនេះហើយដែលធ្វើឱ្យព្រះសង្ឃអាចនិយាយជាមួយមនុស្សទូទៅអំពីបញ្ហាធ្ងន់ធ្ងរទាំងឡាយ។






អ្នកអាចបញ្ឈប់អំពើហិង្សា! បញ្ចប់អំពើហិង្សា ដោយចាប់ផ្តើមពីអ្នក!


សាមណេរសុខារីករាយ
ណាស់ក្នុងនាមជាព្រះសង្ឃ។
អប់រំគ្រួសារនីមួយៗអំពីអំពើ
ហិង្សា បានធ្វើឱ្យលោកមាន
កម្លាំងចិត្ត។ លោកតែងស្រមៃ
អំពីសង្គមមួយដែលគ្មាន
អំពើហិង្សា។

## គណៈកម្មការត្រួតពិនិត្យ និងផ្តល់យោបល់

១. ឯកឧត្តមបណ្ឌិត **មិន ឃិន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

២. ឯកឧត្តមបណ្ឌិត **សេង សុមុនី**
៣. ព្រះញាណវិជ្ជា **ជួន សារឿន**
៤. ព្រះមហារាជធម្ម **ថង្ស អានេតា**
៥. ព្រះសំវរវីជ្ជា **សុខ ម៉ុនធឿន**
៦. លោកជំទាវ **មិន ចណ្ឌីណែត**
៧. លោកជំទាវ **កែវ សុធារី**
៨. លោកស្រី **ជា ម៉ុនយឹង**
៩. លោកស្រី **ហោ ផល្លីន**
១០. លោក **ស្រី សុវណ្ណមុនី**
១១. លោកស្រី **ចាន់ កញ្ញា**

**សេចក្តីណែនាំ** ៖ សៀវភៅរឿង «សាមណេរសុខា» មានទំហំតូចសម្រាប់ព្រះសង្ឃដាក់តាមថង់យាម និងយកទៅជាមួយ នៅពេលនិមន្តទៅតាមភូមិចំណុះជើងវត្ត។ សៀវភៅរឿងនេះ ក៏អាចប្រើសម្រាប់បង្រៀននៅតាមសាលាពុទ្ធកសិក្សាជាតិផងដែរ ៖

១. ព្រះសង្ឃគួរដាក់សៀវភៅរឿង «សាមណេរសុខា» តាមថង់យាម
២. ព្រះសង្ឃគួរអានសៀវភៅរឿង «សាមណេរសុខា» ដើម្បីយល់ដឹងពីអំពើហិង្សា និងកិច្ចការពារកុមារ។
៣. ព្រះសង្ឃគួរប្រើប្រាស់សៀវភៅរឿង «សាមណេរសុខា» ដើម្បីផ្តល់ឱវាទអប់រំដល់ពុទ្ធបរិស័ទ ឬគ្រួសារ អំពីការទប់ស្កាត់អំពើហិង្សាលើកុមារ
៤. សៀវភៅរឿង «សាមណេរសុខា» ក៏អាចប្រើប្រាស់ដើម្បីបង្រៀនសិស្សនៅតាមសាលាពុទ្ធកសិក្សាផងដែរ។

កុមារសុខារស់នៅជាមួយឪពុកម្តាយ ហើយគេទទួលរងនូវអំពើហិង្សាជារៀងរាល់ថ្ងៃ។ ដោយទ្រាំលែងបាន សុខាក៏ទៅពឹងព្រះចៅអធិការឱ្យជួយដោះស្រាយ។ ក្រោយមក គ្រួសារសុខាត្រលប់មករកសុភមង្គលវិញ ហើយសុខាក៏សម្រេចចិត្តបួសជាសាមណេរ។ ដោយក្តីស្វាធ្យាយ សាមណេរសុខាបានជួយអប់រំដល់គ្រួសារជាច្រើន ឱ្យចៀសផុតពីអំពើហិង្សានានាក្នុងសង្គម។

រឿងនេះបង្ហាញពីតួនាទីវត្តអារាម និងព្រះសង្ឃដែលបានជួយកែប្រែជីវិតកុមារ និងគ្រួសារកុមារឲ្យជួបនូវសុភមង្គល។ រឿងនេះបានបង្ហាញផងដែរ នូវការចូលរួមរបស់ពុទ្ធសាសនាក្នុងការកសាងសហគមន៍មួយប្រកបដោយធម៌អហិង្សា។



ISBN: 9 7899963 05 86 3

unicef